00711928

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 07 / 2011
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

E106
E62/3/10

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** សាធារណៈ / Public

ជូនចំពោះ: សហមេធាវីការពារក្តីទាំងអស់ កាលបរិច្ឆេទ:
សហព្រះរាជអាជ្ញា ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១
សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
កម្មវត្ថុ: អនុស្សរណៈជូនចំពោះមេធាវីរបស់ភាគី

នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានទទួលរួចហើយនូវរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹងជនជាប់ចោទ ០៣ (បី) នាក់ ដែលបានលើកឡើងពីបញ្ហាកាយសម្បទារបស់គាត់ក្នុងការចូលរួមដំណើរការសវនាការ ហើយដែលរបាយការណ៍ទាំងនោះត្រូវបានអង្គជំនុំជម្រះចាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់បំផុត។ អង្គជំនុំជម្រះក៏បានជូនដំណឹងផងដែរថា របាយការណ៍ទាំងនោះនឹងត្រូវចាត់ថ្នាក់ឡើងវិញជាប្រភេទឯកសារសម្ងាត់ ក្រោយពេលដែលក្រុមមេធាវីការពារក្តីបានផ្តល់យោបល់ទៅលើរបាយការណ៍របស់សាស្ត្រាចារ្យ Campbell ទាក់ទងទៅនឹងជនជាប់ចោទម្នាក់ៗ ។

នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បានដាក់នូវ "សេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តីទៅនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការដាក់របាយការណ៍

~~E106~~
E62/3/10

វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត Campbell ទៅក្នុងផ្នែកសម្ងាត់នៃសំណុំរឿង" (ឯកសារ E62/3/7)។ ថ្ងៃនេះ ក្រុមមេធាវីការពារក្ដី នួន ជា បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនារបស់ខ្លួនក្នុងការចូលរួមការជំទាស់នេះ។ ការជំទាស់នេះនឹងដាក់ចូលក្នុងសំណុំរឿងក្នុងពេលឆាប់ៗ។ ក្នុងគោលបំណងដើម្បីធានាថា កិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយឆាប់រហ័ស អង្គជំនុំជម្រះចាត់ទុកថា បញ្ហានៃការធ្វើចំណាត់ថ្នាក់ឯកសារនេះគឺជាបញ្ហាមួយដែលត្រូវធ្វើការសម្រេចឲ្យបានឆាប់ ។

ដោយទទួលស្គាល់ថា ការិយាល័យសហព្រះរាជអាជ្ញាត្រូវទទួលបានរបាយការណ៍អ្នកជំនាញនេះពេញលេញ ដើម្បីធ្វើការសម្រេចថា គាំទ្រ ឬជំទាស់ទៅនឹងការវាយតម្លៃនេះ ហើយក្រុមមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ និង នួន ជា ក៏បានយល់ព្រមឲ្យអង្គជំនុំជម្រះបញ្ជូនរបាយការណ៍នេះទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីធ្វើការឆ្លើយតបក្នុងរយៈពេលដែលបានកំណត់ផងដែរ ។

អង្គជំនុំជម្រះកត់សម្គាល់អំពីសារៈសំខាន់ដែលថា ភាគីទាំងអស់មានឱកាសដើម្បីផ្ដល់យោបល់គាំទ្រ ឬជំទាស់ទៅនឹងការយល់ឃើញផ្នែកវេជ្ជសាស្ត្ររបស់អ្នកជំនាញ ដោយធ្វើការថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវភាពសម្ងាត់ឯកជនរបស់ខ្លួនអំពីព័ត៌មានខាងផ្នែកវេជ្ជសាស្ត្រ ជាមួយនឹងសិទ្ធិរបស់សាធារណៈជនក្នុងការដឹងអំពីមូលដ្ឋានក្នុងការកំណត់ថា ហេតុអ្វីបានជាជនជាប់ចោទស្នើសុំមិនចូលរួមដំណើរការសវនាការដោយសារតែមិនមានកាយសម្បទាគ្រប់គ្រាន់។ ដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងមិនធ្វើចំណាត់ថ្នាក់ឡើងវិញនូវរបាយការណ៍ទាំងនេះរបស់អ្នកជំនាញទាក់ទងនឹង អៀង ធីរិទ្ធ និង នួន ជា ទៅជាប្រភេទឯកសារសម្ងាត់នោះទេ ប៉ុន្តែអង្គជំនុំជម្រះនឹងកម្រិតការចែកជូនព័ត៌មាននេះទៅឲ្យមេធាវីរបស់ភាគី ក្នុងគោលបំណងផ្ដល់ឱកាសដល់ពួកគេដើម្បីពិនិត្យមើលរបាយការណ៍ទាំងមូល នឹងដើម្បីធ្វើការចង្អុលបង្ហាញអំពីការគាំទ្រ ឬជំទាស់ទៅលើសំណើរបស់ អៀង ធីរិទ្ធ និង នួន ជា ។

ហេតុដូច្នេះ អង្គជំនុំជម្រះសូមបញ្ជាក់ថា របាយការណ៍របស់អ្នកជំនាញទាក់ទងនឹង អៀង ធីរិទ្ធ និង នួន ជា ត្រូវចាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់បំផុតដដែល ដោយរង់ចាំនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅពេលខាងមុខ។ អង្គជំនុំជម្រះសូមបង្គាប់ផងដែរថា មានតែសហព្រះរាជអាជ្ញា មេធាវីការពារក្ដីរបស់ជនជាប់ចោទម្នាក់ៗ និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ នឹងទទួលបានរបាយការណ៍នេះរបស់អ្នកជំនាញទាក់ទងទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា

00711930

~~E106~~
E62/3/10

ជាអត្ថបទចម្លងពេញលេញ។ អង្គជំនុំជម្រះក៏សូមណែនាំផងដែរថា របាយការណ៍ទាំងនេះមិនត្រូវប្រគល់ទៅឱ្យជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ឡើយ ។

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ច្បាប់ចម្លងនៃរបាយការណ៍ទាំងនេះទៅឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាមួយបាន តែក្នុងករណីមានការព្រមព្រៀងរវាងមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ១២ ស្ទួនពីរ (៥) (ខ) និង (៦) ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះនឹងធ្វើនូវសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីរួមក្រុមប៉ុណ្ណោះ។ ក្នុងករណីនេះ អង្គជំនុំជម្រះក៏សូមណែនាំដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរថា របាយការណ៍ទាំងនេះគឺនៅតែត្រូវបានធ្វើចំណាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់បំផុតដដែល ហើយមិនត្រូវផ្សព្វផ្សាយរបាយការណ៍ទាំងនេះទៅឱ្យបុគ្គលផ្សេងទៀតឡើយ។